# យើងត្រូវការឱ្យអ្នកចាត់វិធានការ ដើម្បីធានាយ៉ាងណាឱ្យមាន ការប្រើប្រាស់ឱសថប្រឆាំងមេរោគ ប្រកបដោយការប្រុងប្រយ័ត្ន។

កសិករ

ឱសថប្រឆាំងមេរោគគឺជា **ឱសថសារវន្ត** សម្រាប់ទប់ស្កាត់ និងព្យាបាលជំងឺឆ្លង ទាំងក្នុងខ្លួនមនុស្ស និងទាំងក្នុងខ្លួនសត្វ។

ប៉ុន្តែឱសថប្រឆាំងមេរោគកំពុងបាតបង់ **ប្រសិទ្ធភាពរបស់វា** ក្នុងល្បឿនមួយកាន់តែលឿនដោយសារការប្រើលើសលប់ និងការប្រើប្រាស់មិនត្រឹមត្រូវ។

## អ្វីដែលអ្នកចាំបាច់ត្រូវដឹង៖

- ហានិភ័យដែលភ្នាក់ងារបង្កជំងឺនឹងបង្កើតភាពស៊ាំនឹងឱសថប្រឆាំងមេរោគ មានការកើនឡើងនៅពេលដែលឱសថ ដ៏មានតម្លៃទាំងនេះ ត្រូវបានគេប្រើលើសលប់ ឬប្រើប្រាស់មិនសមស្រប។ បន្ទាប់ពីបាក់តេរីមានភាពស៊ាំឱសថ ប្រឆាំងមេរោគលែងមានប្រសិទ្ធភាពទៀត និងពុំអាចព្យាបាលជំងឺជានោះឡើយ។ បាតុភូតនេះហៅថា ភាពស៊ាំ នឹងឱសថប្រឆាំងមេរោគ (ឬហៅកាត់ជាភាសាអង់គ្លេសថា AMR)។
- ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាការគំរាមកំហែងចំពោះសុខភាព និងសុខុមាលភាពរបស់មនុស្ស និងសត្វមិនថាជាសត្វរស់នៅក្នុងទឹក ឬសត្វរស់នៅលើគោកនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតឱសថប្រឆាំងមេរោគថ្មីពុំអាចតាមទាន់ការកើនឡើងនូវភាពស៊ាំនឹងឱសថនេះឡើយ។ យើងត្រូវការពារអ្វីដែលយើងមាននាពេលបច្ចុប្បន្ន!
- ការបន្តភាពអាចរកបាន និងប្រសិទ្ធភាពនៃឱសថប្រឆាំងមេរោគបច្ចុប្បន្នមានសារៈសំខាន់យ៉ាងខ្លាំង។ ការប្រើប្រាស់ឱសថដ៏មានតម្លៃទាំងនេះ ប្រកបដោយការទទួលខុសត្រូវ និងដោយមានការប្រុងប្រយ័ត្នទៅតាមស្តង់ដាររបស់អង្គការសុខភាពសត្វពិភពលោក (OIE) ដែលជាអង្គការអន្តររដ្ឋាភិបាល នឹងជួយបន្តឱ្យឱសថទាំងនេះមានប្រសិទ្ធភាព និងនៅតែអាចប្រើប្រាស់បាន សម្រាប់ទាំងសុខភាពមនុស្ស និងសុខភាពសត្វ។

## យើងត្រូវការ អ្នក



“យើងទាំងអស់គ្នាសុទ្ធតែមានតួនាទី ដែលត្រូវបំពេញហើយក្នុងនាមអ្នកជា **អ្នកប្រើប្រាស់** ឱសថប្រឆាំងមេរោគ **អ្នកអាចជួយដល់យើងបាន**”

- យើងចាំបាច់ត្រូវរួមគ្នាធានា ឱ្យមានការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយការទទួលខុសត្រូវ និងប្រុងប្រយ័ត្នលើសត្វ ដើម្បីរក្សា ភាពអាចរកបាន និងប្រសិទ្ធភាពនៃឱសថប្រឆាំងមេរោគទាំងនេះ ដែលជួយការពារសុខភាព និងសុខុមាលភាពរបស់មនុស្ស និងសត្វ។ តាមរយៈការផ្តល់អាទិភាពដល់ការគោរពតាមការអនុវត្តន៍ល្អលើការចិញ្ចឹមសត្វ ជីវសុវត្ថិភាព ការចាក់ថ្នាំបង្ការ និងការរក្សាអនាម័យឱ្យបានល្អ យើងអាចជួយថែទាំសុខភាពសត្វបាន។

- ការឆ្លើយតប ចំពោះបញ្ហាមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាគោលបំណងអាទិភាពមួយ របស់អង្គការសុខភាពសត្វពិភពលោក (ហៅកាត់ថា OIE)។ តាមរយៈស្តង់ដារអន្តរជាតិរបស់ខ្លួន OIE ជំរុញឱ្យមានការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយការទទួលខុសត្រូវ និងប្រុងប្រយ័ត្ន ព្រោះវាមានសារៈសំខាន់ចំពោះសុខភាព និងសុខុមាលភាពរបស់មនុស្ស និងសត្វ ពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធនឹងសុខភាពសត្វទាំងអស់ រួមបញ្ចូលទាំងម្ចាស់សត្វ និងកសិករផងដែរ។

@ សម្រាប់ព័ត៌មានបន្ថែម៖ **www.oie.int/amrstandards**

# ម្ចាស់សត្វ៖
# អ្នកគឺជាអ្នកចិញ្ចឹមសត្វ

កសិករ

- ក្នុងនាមជាម្ចាស់សត្វដែលផ្គត់ផ្គង់ស្បៀងអាហារ មិនថាអ្នកចិញ្ចឹមសត្វខ្នាតតូច អ្នកចិញ្ចឹមត្រី ឬអ្នកចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនោះទេ អ្នកបំពេញតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ស្បៀងអាហារដល់មនុស្ស។ អ្នកគឺជាអ្នកទទួលខុសត្រូវក្នុងការផ្តល់កសិផលប្រកបដោយសុវត្ថិភាព និងនាំមកនូវសុខភាពល្អ ដល់អ្នកប្រើប្រាស់ ដោយអ្នកត្រូវមើលថែសុខភាព និងសុខុមាលភាពសត្វរបស់អ្នក។
- ការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ និងដោយប្រុងប្រយ័ត្ន រួមមានការគោរពតាមវិធានការ និងអនុសាសន៍ក្នុងគោលបំណងលើកកម្ពស់សុខភាព និងសុខុមាលភាពសត្វ ហើយក្នុងពេលជាមួយគ្នា អាចទប់ស្កាត់ ឬកាត់បន្ថយការជ្រើសរើសការលេចឡើង និងការសាយភាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ សូមធ្វើសកម្មភាពនៅថ្ងៃនេះ ដើម្បីការពារប្រសិទ្ធភាពឱសថប្រឆាំងមេរោគនាពេលអនាគត។

## កសិករ និងម្ចាស់សត្វ ត្រូវ៖

១ **ប្រើប្រាស់ឱសថប្រឆាំងមេរោគ តែនៅពេលដែលមានវេជ្ជបញ្ជាពីបសុពេទ្យ** (ឬ អ្នកដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងដែលទទួលបានការអនុញ្ញាតឱ្យចេញវេជ្ជបញ្ជាបសុឱសថ) តែប៉ុណ្ណោះ។ មិនមែនគ្រប់ជំងឺទាំងអស់សុទ្ធតែត្រូវព្យាបាល ដោយប្រើប្រាស់ឱសថប្រឆាំងមេរោគនោះឡើយ។

២ សូមធ្វើតាម **ការណែនាំអំពីកម្រិតប្រើប្រាស់** ត្រឹមត្រូវដែលចេញដោយបសុពេទ្យ។

៣ ផ្តល់ថ្នាំព្យាបាលទៅតាម **រយៈពេលដែលកំណត់** ក្នុងវេជ្ជបញ្ជា បើទោះបីជាសត្វហាក់បីដូចជាបានធូរស្បើយហើយក៏ដោយ។

៤ សូមស្វែងរក **ឱសថប្រឆាំងមេរោគ តែពីប្រភពដែលមានការអនុញ្ញាត** ត្រឹមត្រូវ ដើម្បីធានាគុណភាពនៃផលិតផល។

៥ **គោរពតាមការអនុវត្តន៍ល្អលើការចិញ្ចឹមសត្វ ជីវសុវត្ថិភាព និងការគ្រប់គ្រងសត្វ។** ម្ចាស់សត្វគួររៀបចំផែនការ សុខភាពសម្រាប់សត្វរបស់ពួកគេជាមួយនឹងបសុពេទ្យ ឬអ្នកជំនាញខាងសុខភាពសត្វ ដើម្បីការពារសត្វរបស់ពួកគេពីជំងឺឆ្លង។

៦ រក្សា **កំណត់ត្រាលាយលក្ខណ៍អក្សរ ឱ្យបានគ្រប់គ្រាន់ អំពីឱសថប្រឆាំងមេរោគទាំងអស់** ដែលត្រូវបានប្រើប្រាស់ និងលទ្ធផលចេញពីមន្ទីរពិសោធន៍។

@ សម្រាប់ព័ត៌មានបន្ថែម៖ **www.oie.int/amrstandards**




Funded by UK Government

WORLD ORGANISATION FOR ANIMAL HEALTH
*Protecting animals, preserving our future*